ក្រសួងកិច្ចការនារី
MINISTRY OF WOMEN'S AFFAIRS

## បទបង្ហាញ ស្ដីពី

# ការបញ្ជ្រាបយេនឌ័រ នៅថ្នាក់ឃុំ សង្កាត់

*«ដើម្បីសមភាពយេនឌ័រ និងទាញយកអត្ថប្រយោជន៍ពី
ភាគលាភយេនឌ័រនៅថ្នាក់មូលដ្ឋាន»*

# មាតិកា

1. វិធីសាស្ត្របញ្ជ្រាបយេនឌ័រ
2. ក្របខ័ណ្ឌគោលនយោបាយ និងការប្តេជ្ញាចិត្ត
3. គុណតម្លៃ និងភាគលាភយេនឌ័រ ក្នុងការបញ្ជ្រាបយេនឌ័រនៅថ្នាក់ឃុំ សង្កាត់
4. ទិសដៅអាទិភាព នៅថ្នាក់ឃុំ សង្កាត់

ផ្នែកទី ១

# វិធីសាស្រ្ត ក្នុងការបញ្រ្ជាបយេនឌ័រ

## សមភាពយេនឌ័រ

សមភាពរបស់កូនប្រុស កូនស្រី បុរស ស្រ្តីទទួលបាននូវឱកាសសិទ្ធិ អំណាច និងផលប្រយោជន៍

### ១. ផ្លាស់ប្តូរផ្នត់គំនិត និងឥរិយាបថអវិជ្ជមាន (ហេតុ)

- បង្ហាញនិងពន្យល់ហេតុផល (ចំណុចល្អ និងចំណុចមិនល្អ)
- ដាក់ចេញនូវច្បាប់ គោលនយោបាយ និងវិធានការនានា រួមទាំងយន្តការ ជំរុញ និងតាមដាន
- បង្ហាញនូវភាពគំរូ

### ២. គាំទ្រក្រុមដែលរងគ្រោះ និងងាយបាត់ឱកាស (ដូចជាស្រ្តី និងក្មេងស្រី)

- សកម្មភាពវិជ្ជមានបណ្តោះអាសន្ន ដូចជាប្រព័ន្ធកូតាកំណត់ចំនួន ពង្រឹងសមត្ថភាព..)
- ចាត់វិធានការទប់ស្កាត់ការរើសអើង និងគំលាត
- ឆ្លើយតបនឹងបញ្ហាដែលកើតមានដល់ស្រ្តី និងក្មេងស្រី។

# សមភាពយេនឌ័រ

ជាការទទួលខុសត្រូវ និងមានសារៈសំខាន់សម្រាប់យើងទាំងអស់គ្នា

1. **សិទ្ធិស្មើគ្នា៖** តាមគោលការណ៍សកលអំពីសិទ្ធិមនុស្ស និងមានចែងក្នុងរដ្ឋធម្មនុញ្ញ

2. **សំដៅដល់ការលើកកម្ពស់សមភាព** ការទទួលនូវឱកាស មានជម្រើស ការចូលរួម និងភាពជាតំណាង (សម្លេង) ដល់បុគ្គលគ្រប់រូប

3. **លុបបំបាត់ភាពងាយរងគ្រោះ**របស់បុគ្គលគ្រប់រូប និង**ការរើសអើងគ្រប់ទម្រង់** ដែលកើតចេញពីផ្នត់គំនិតយេនឌ័រ

4. ក្នុងបរិបទសកលភាវូនីយកម្ម, ភាពប្រកួតប្រជែងដែលពឹងផ្អែកលើ**គុណភាពធនធានមនុស្ស (ទាំងស្ត្រី ទាំងបុរស និងបុគ្គលគ្រប់រូប មានសារៈសំខាន់** ដែលត្រូវការភាពសកម្ម សមត្ថភាព និងភាពធន់

5. **ភាពជាដៃគូ និងការរស់នៅប្រកបដោយសមភាព និងសមធម៌** គឺជា**តម្លៃដែលនាំមកនូវភាពប្រសើរឡើងនូវជីវភាពរស់នៅ** និងចំណេះដឹងរបស់គ្រួសារ សុខុមាលភាពនៅក្នុងសង្គម និងសេដ្ឋកិច្ចប្រសើរឡើង។

ផ្នែកទី ២

# ការគាំទ្រកម្រិតគោលនយោបាយ និងពីថ្នាក់ដឹកនាំ



**សម្ដេចតេជោ** តែងតែលើកឡើងថា ជួយស្ត្រី គឺជួយខ្លួនឯង, ស្ត្រី ជាផ្នែកដ៏សំខាន់នៃធនធានមនុស្សកម្ពុជា

- ដោយចាត់ទុក ស្ត្រី គឺជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចនិងសង្គមជាតិ
- តាមរយៈយុទ្ធសាស្ត្រចតុកោណ ទាំង៤ដំណាក់កាល។

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
អតីតនាយករដ្ឋមន្ត្រី និងជាប្រធានព្រឹទ្ធសភា



**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី** បានលើកឡើងថា «**រាជរដ្ឋាភិបាលកម្ពុជានឹងបន្តនូវមរតកដ៏ថ្លៃថ្លារបស់សម្តេចតេជោ ហ៊ុន សែន** តាមរយៈការបន្តជំរុញនិងលើកកម្ពស់បន្ថែមទៀតដល់**តួនាទីរបស់ស្ត្រីនៅក្នុងសង្គមជាតិ និងផ្តល់តម្លៃខ្ពស់ដល់តួនាទីរបស់ស្ត្រី ក្នុងការចូលរួមអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម**»។

តាមរយៈការដាក់ចេញនូវ**យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី ១** រាជរដ្ឋាភិបាល នឹងពង្រឹងភាពជាពលរដ្ឋក្នុងសង្គមដែលមានអារ្យធម៌ខ្ពស់ ប្រកបដោយសីលធម៌ សមធម៌ និងបរិយាបន្ន ដែលក្នុងនោះ **ស្ត្រីគឺជាស្នូល**។

**រាជរដ្ឋាភិបាល បន្តបង្កើនការវិនិយោគលើយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រីក្នុង**វិស័យ**សេដ្ឋកិច្ច អប់រំ សុខភាព និងការដឹកនាំសាធារណៈ** ដើម្បីទាញយកអត្ថប្រយោជន៍ពី**ភាគលាភយេនឌ័រ** ។

# ភាគលាភយេនឌ័រ ( Gender Dividend )

សំដៅលើ **ផលតម្លៃ ដល់សេដ្ឋកិច្ច និងសង្គម ឬនៅតាមវិស័យ**

ដែលកើតឡើង → ពេល**គម្លាតយេនឌ័រ** ត្រូវបានដោះស្រាយ

ជាពិសេសលើការចូលរួមក្នុង**កម្លាំងពលកម្ម និងការងារ, អប់រំ និងភាពជាអ្នកដឹកនាំ។**

   

ផ្នែកទី ៣

# គុណតម្លៃ និងភាគលាភយេនឌ័រ

## *ក្នុងការបញ្ជ្រាបយេនឌ័រ នៅថ្នាក់ឃុំ សង្កាត់*

រដ្ឋបាលឃុំ-សង្កាត់ គឺជាអភិបាលកិច្ចថ្នាក់មូលដ្ឋាន ដែលនៅជិតប្រជាពលរដ្ឋ និង ជាតួអង្គយុទ្ធសាស្ត្រ ក្នុងការបំប្លែង «គោលនយោបាយ និងចក្ខុវិស័យរបស់ជាតិ» ទៅជា «សកម្មភាពជាក់ស្តែង»។

ការបញ្ជ្រាបយេនឌ័រ នៅថ្នាក់ឃុំ សង្កាត់
ជាវិធីសាស្ត្រ ដើម្បីសមភាពយេនឌ័រ និងទាញយកអត្ថប្រយោជន៍ពីភាគលាភយេនឌ័រ ដែលផ្តល់ផល និងគុណតម្លៃជាពហុវិស័យ
ក្នុងកិច្ចអភិវឌ្ឍនៅថ្នាក់មូលដ្ឋាន។

# ភាគលាភយេនឌ័រ សម្រាប់ឃុំ សង្កាត់

## ការលើកកម្ពស់អភិបាលកិច្ច និងសេវាសាធារណៈមូលដ្ឋាន

- **ភាពចម្រុះ** -> ធ្វើឱ្យអាទិភាពថវិកា និងគម្រោងអភិវឌ្ឍន៍ បានឆ្លើយតបកាន់តែទូលំទូលាយដល់តម្រូវការសហគមន៍
- ការចូលរួមរបស់ស្ត្រី ក្នុងក្រុមប្រឹក្សាឃុំ-សង្កាត់ និងគណៈកម្មាធិការនានា -> **បង្កើនទុកចិត្តពីសាធារណជន និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ**
- យន្តការដឹកនាំ និងដោះស្រាយវិវាទក្នុងមូលដ្ឋាន ដែលមានសមាសភាពចម្រុះ បុរសស្ត្រី -> **បង្កើនវប្បធម៌សម្របសម្រួលយោគយល់ និងអហិង្សាខ្ពស់។**

## ការពង្រឹងមូលធនមនុស្ស និងសុខុមាលភាពសង្គម

- **ការលើកកម្ពស់សុខភាពមាតា-ទារក និងអាហាររូបត្ថម្ភ** ជួយកាត់បន្ថយអត្រាស្លាប់និងគ្រោះថ្នាក់សុខភាពក្នុងសហគមន៍
- **សមភាពនៃការទទួលបានការអប់រំ៖** ជួយជំរុញឱ្យកុមារ ( ទាំងប្រុស ទាំងស្រី ) ទទួលបានការអប់រំប្រកបដោយគុណភាព កាត់បន្ថយអត្រាបោះបង់  ការសិក្សា និងបង្កើតកម្លាំងពលកម្មជំនាញ
- **ការកាត់បន្ថយអំពើហិង្សាក្នុងគ្រួសារ** អំពើហិង្សាទាក់ទងនឹងយេនឌ័រ និងបង្កើតបរិយាកាសរស់នៅប្រកបដោយសុវត្ថិភាព។

## កំណើនសេដ្ឋកិច្ច និងផលិតភាពក្នុងមូលដ្ឋាន

- ការគាំទ្រស្ត្រីឱ្យទទួលជំនាញ ដើមទុន និងទីផ្សារ **ជួយបង្កើនប្រាក់ចំណូលគ្រួសារដោយផ្ទាល់ និងបង្កើនលទ្ធភាពនឹងវិបត្តិសេដ្ឋកិច្ច**
- **ធ្វើឱ្យមានការរីកចម្រើន នៃសហគ្រាសធុនមីក្រូ តូច និងមធ្យម៖** ការលើកកម្ពស់សហគ្រិនភាពស្ត្រីក្នុងស្រុក **ជួយបង្កើតការងារ ជំរុញចរន្តសេដ្ឋកិច្ចក្នុងសហគមន៍**
- **ការទទួលស្គាល់ និងការរៀបចំឡើងវិញនូវការងារថែទាំគ្មានកម្រៃ** ដូចជាការបង្កើតសេវាថែទាំកុមារ ឬទារកដ្ឋានសហគមន៍ ជួយស្ត្រីឱ្យមានឱកាសចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច បង្កើតចំណូល និងការងារសាធារណៈ។

ផ្នែកទី ៤

# កិច្ចការអាទិភាព ទាំង៦

1. បង្កើនសមាមាត្រ ការចូលរួម និងអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំរបស់ស្ត្រី និងក្មេងស្រី នៅក្នុងកិច្ចការក្រុមប្រឹក្សាឃុំ-សង្កាត់ ថ្នាក់ដឹកនាំភូមិ សហគមន៍ និងនៅតាមគ្រួសារ
2. ការពង្រឹងយន្តការសេវាសង្គម, ប្រតិបត្តិការរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ-សង្កាត់ និងការបញ្ជ្រាបយេនឌ័រ ក្នុងកិច្ចការរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។
3. ការអភិវឌ្ឍសេដ្ឋកិច្ចគ្រួសារ និងសហគ្រិនភាពស្ត្រី ក្នុងសហគ្រាសធុនមីក្រូ តូច និងមធ្យម លើការបណ្តុះបណ្តាលជំនាញបច្ចេកវិទ្យា-ឌីជីថល ហិរញ្ញវត្ថុ និងទីផ្សារដល់ស្ត្រី

# កិច្ចការអាទិភាព ទាំង៦ (ត)

4. **ការទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ ព្រមទាំងការផ្លាស់ប្តូរផ្នត់គំនិត និងការលុបបំបាត់ការរើសអើងលើស្ត្រីនិងក្មេងស្រី** ដោយចាប់ផ្តើមពីកម្រិតគ្រួសារ សហគមន៍ តាមរយៈការអប់រំ និងការលើកកម្ពស់សីលធម៌សង្គម
5. **ការកាត់បន្ថយនិងចែករំលែក«ការងារថែទាំក្នុងគ្រួសារ»** ពង្រីកសេវាថែទាំកុមារ/ទារកដ្ឋានសហគមន៍និងជំរុញយុទ្ធនាការកាត់បន្ថយ និងចែករំលែកការងារផ្ទះ រវាងបុរសនិងស្ត្រី ក្នុងគ្រួសារ
6. **ការពង្រឹងភាពជាពលរដ្ឋ និងគ្រួសារគំរូ:** ផ្សព្វផ្សាយ និងលើកកម្ពស់ភាពជាមាតាបិតា ការចិញ្ចឹមកូនបែបវិជ្ជមាន ការបង្កើតទំនាក់ទំនងអន្តរជំនាន់ និងការបណ្តុះវប្បធម៌អហិង្សាក្នុងគ្រួសារ សហគមន៍ និងសង្គម។

# សន្និដ្ឋាន



ការបញ្ច្រាបយេនឌ័រ៖

1. ការលើកកម្ពស់**អភិបាលកិច្ច** និង**សេវាសាធារណៈមូលដ្ឋាន**
2. ការពង្រឹង**មូលធនមនុស្ស** និង**សុខុមាលភាពសង្គម**
3. កំណើន**សេដ្ឋកិច្ច** និង**ផលិតភាព**ក្នុងមូលដ្ឋាន។

→ កត្តាចាំបាច់ និងជាមូលដ្ឋានគ្រឹះក្នុងការធ្វើឱ្យគ្រួសារ និងសហគមន៍ **មានភាពធន់ខ្ពស់** និង**សមត្ថភាពឆ្លើយតបនឹងការវិវត្តរបស់សង្គម** ការប្រែប្រួលអាកាសធាតុ និងបញ្ហាប្រឈមនានា។

**សុខុមាលភាពរបស់ពលរដ្ឋ និងកម្លាំងនៃកំណើនសេដ្ឋកិច្ច → កើតចេញពីគ្រួសារ និងសហគមន៍នីមួយៗ ក៏ដូចជាឃុំ សង្កាត់ ដែលជាចំណែកសំខាន់ →** ជួយបង្កើនផលិតផលក្នុងស្រុកសរុប (GDP), + ការអភិវឌ្ឍសង្គម + ជំរុញកម្ពុជាឱ្យសម្រេចបាននូវចក្ខុវិស័យរយៈពេលវែង។